UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

២៧ មករា ២០១២

## រាជរដ្ឋាភិបាល និង ការិយាល័យOHCHR ព្រមព្រៀងបន្តការងាររួមគ្នា

រាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុក សិទ្ធិមនុស្ស បានចុះអនុស្សារណៈយោគយល់គ្នា(MOU) ដើម្បីបន្តពេលអនុវត្តកម្មវិធីសហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្សនៅក្នុងប្រទេសដោយភាគីទាំងពីរ សំរាប់រយៈពេលពីរឆ្នាំទៀត។

អនុស្សារណៈនេះ ត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម ហោ ណាំហុង** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង **លោកស្រី ណាវី ភីឡៃ** ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ដែលមានសុពលភាពរយៈពេលពីរឆ្នាំ ចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១២ នេះតទៅ។ អនុស្សារណៈកន្លងមក បានផុតកំណត់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១។

ការវិវឌ្ឍន៍ថ្មីមួយទៀតគឺ លោកស្រីឧត្តមស្នងការបានតែងតាំង **លោកស្រី វ៉ាន់ ហ៊ី លី** ជាតំណាងថ្មីរបស់លោកស្រីប្រចាំនៅកម្ពុជា។ បច្ចុប្បន្ន **លោកស្រី លី** កាន់មុខតំណែងជាន់ខ្ពស់មួយនៅផ្នែកសន្ធិសញ្ញាសិទ្ធិមនុស្ស នៅទីស្នាក់ការកណ្តាលនៃការិយាល័យ OHCHR ហើយលោកស្រីមានបទពិសោធន៍ច្រើនទូលំទូលាយជាមួយការិយាល័យតំណាងរបស់ OHCHR ប្រចាំនៅប្រទេសម៉ុងហ្គោលី ការិយាល័យថ្នាក់តំបន់នៅទីក្រុងបាងកក និងនៅប្រទេសប៊ឺរ៉ុនឌី។ លោកស្រីនឹងចូលកាន់មុខតំណែងនេះ នៅពាក់កណ្តាលឆ្នាំ ២០១២។

ស្ថិតក្រោមអនុស្សារណៈនេះ កម្មវិធីសហប្រតិបត្តិការផ្នែកបច្ចេកទេស មានគោលដៅពង្រឹងបន្ថែមទៀតនូវសមត្ថភាពរបស់ស្ថាប័នរដ្ឋាភិបាល និងស្ថាប័នមិនមែនរដ្ឋាភិបាល ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស

នៅកម្ពុជា។ ការិយាល័យ OHCHR នឹងបន្តអនុវត្តគំរោងការផ្សេងៗដែលរាប់ទាំងការធ្វើសមាហរណកម្ម វិសាលភាពសិទ្ធិមនុស្សទៅក្នុងវិស័យអប់រំ សុខភាព និង ការអភិវឌ្ឍន៍ដទៃផ្សេងទៀត បន្តការបណ្តុះបណ្តាលដល់មន្រ្តីប្រតិបត្តិច្បាប់ និងមន្រ្តីនៃកងកំលាំងប្រដាប់អាវុធ និងផ្តល់កិច្ចគាំពារផ្នែកបច្ចេកទេសសំរាប់កម្មវិធីកំណែទម្រង់របស់រដ្ឋាភិបាល រាប់ទាំងក្នុងវិស័យគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ និងដំណើរការនីតិកម្ម និងជំរុញលើកទឹកចិត្តឲ្យមានការចូលរួមពីសង្គមស៊ីវិល និងលើកកំពស់ការអប់សាធារណៈជនអំពីលិទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្ស។

*សំរាប់ព័ត៌មានបន្ថែម សូមមេត្តាទំនាក់ទំនងមក* ***កញ្ញា ហ្ស៊ូអ៊ី ឡាធំបូ*** *តាមរយៈទូរស័ព្ទលេខ (+៨៥៥) ០១២ ៧៩០ ១៧៨ ឬ តាមរយៈអ៊ីម៉េល zlatumbo@ohchr.org ។*

The Office of the High Commissioner for Human Rights (OHCHR) is the principal United Nations agency responsible for the promotion and protection of human rights. OHCHR has been operating in Cambodia since 1993.

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

United Nations Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia